**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងស្តីពីការព្យួរកិច្ចសន្យាការងារ

រោងចក្រ ហុង វ៉ា (កម្ពុជា) ហ្គាមិន ម៉ាញូហ្វាក់ឆឺរីងលីមីធីត (សាខាទី ២) ដែលមានលោក ចាន់ វ៉ែន នាយករោងចក្រជាតំណាងហៅកាត់ថា ភាគី "ក" ។

និង

តំណាងកម្មករ - សហជីព ប្រចាំរោងចក្រ ហុង វ៉ា (កម្ពុជា) ហ្គាមិន ម៉ាញូហ្វាក់ឆឺរីងលីមីធីត (សាខាទី ២) ហៅកាត់ថា ភាគី "ខ" ។

ក្រោយពីកិច្ចប្រជុំពិភាក្សាគ្នារួច ភាគីទាំងពីរបានព្រមព្រៀង និងឯកភាពគ្នាតាមប្រការ និងលក្ខខណ្ឌ ដូចខាងក្រោម៖

ប្រការ១. ភាគី "ក" នឹងរៀបចំព្យួរកិច្ចសន្យាការងាររបស់កម្មករ-និយោជិតចំនួន ១០៩ នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ១៥៧ នាក់ ដោយមូលហេតុរោងចក្រខ្វះនូវសម្ភារៈ វត្ថុធាតុដើមសម្រាប់ផលិត និងខ្វះអ្នកបញ្ជាទិញ ទើបបណ្តាលអោយខាងរោងចក្រពុំមានការងារធ្វើគ្រប់គ្រាន់រយៈពេល ០២ខែ គិតចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០២០ ។

ប្រការ២. ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារនេះ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម ជូនដល់កម្មករនិយោជិតក្នុងម្នាក់ៗចំនួន ៣០ដុល្លារអាមេរិក ។ ក្នុងករណីខាងក្រសួង មានសេចក្តីជូនដំណឹងថ្មីបន្ថែមតាមក្រោយទៀតនោះខាងក្រុមហ៊ុន និងអនុវត្តទៅតាមការ ណែនាំថ្មីៗនោះជាក់ស្តែង ។

ប្រការ៣. ភាគី "ក" ត្រូវបើកប្រាក់ព្យួរកិច្ចសន្យាការងារនេះនៅថ្ងៃទី ០៩ នៃខែបន្ទាប់ ។

ប្រការ៤. ភាគី "ខ" ត្រូវត្រឡប់ចូលធ្វើការវិញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០២០ ចំពោះអ្នកដែល មិនបានត្រឡប់មកតាមកាលកំណត់ទេ នឹងត្រូវចាត់ទុកថាអវត្តមានដោយអត់ច្បាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមេសា ឆ្នាំ២០២០

| | |
|---|---|
| ហត្ថលេខា ឬស្នាមមេដៃ | ហត្ថលេខា |
| ភាគី "ខ" | ភាគី "ក" |
| | HUNG WAH (CAMBODIA) GARMENT MANUFACTURING LTD. |
| | ចាន់ វ៉ែន |

ស្នាមមេដៃតំណាងកម្មករ - សហជីព

លោក ភួង កញ្ញា



លោក ព្រំ សឿន



លោក អ៊ិន កុសល់

